# ឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា៖ ខិត្តប័ណ្ណព័ត៌មាន




## តើច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យាជាអ្វី?

ច្បាប់ស្តីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យាជាផ្នែកមួយនៃច្បាប់ដែលកំពុងត្រូវបានធ្វើសេចក្តីព្រាង ដោយរាជរដ្ឋាភិបាលកម្ពុជាដើម្បីគ្រប់គ្រងសកម្មភាពលើប្រព័ន្ធអ៊ិនធើណែត។ រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងធ្វើសេចក្តីព្រាងច្បាប់នេះយ៉ាងហោចណាស់តាំងពីឆ្នាំ២០១២។

## តើវានឹងប៉ះពាល់ខ្ញុំដូចម្តេច?

យើងពិតជាមិនអាចដឹងទេ ពីព្រោះរដ្ឋាភិបាលមិនទាន់បានបញ្ចេញជាផ្លូវការនូវសេចក្តីព្រាងច្បាប់នេះនៅឡើយ។ ប៉ុន្តែ ច្បាប់ចំលងមិនផ្លូវ ការនៃសេចក្តីព្រាងច្បាប់នេះបានលេចធ្លាយកាលពីឆ្នាំមុន ហើយដែលធ្វើអោយមានការព្រួយបារម្ភ រួមទាំងការភ័យខ្លាចថា ច្បាប់នេះអាចជា៖

**អនុញ្ញាតិអោយរដ្ឋាភិបាលត្រួតពិនិត្យសកម្មភាពលើប្រព័ន្ធអ៊ិនធើណែត៖** សេចក្តីព្រាងច្បាប់នេះផ្តល់អំណាចអោយដល់ក្រុមមួយនៃរដ្ឋាភិបាលដែលមាននាយករដ្ឋមន្ត្រីជាប្រមុខ និងប៉ូលីស ធ្វើការសើបអង្កេតឧក្រិដ្ឋកម្មលើប្រព័ន្ធអ៊ិនធើណែត។ គណកម្មការនេះធ្វើការស្រាវជ្រាវ រឹបអូសកុំព្យូទ័រ ទូរស័ព្ទ និងអាចឃ្លាំមើលការទំនាក់ទំនងតាមប្រព័ន្ធអ៊ិនធើណែតដោយមិនចាំបាច់មានដេការ។



**ជាការរិតត្បិតសេរីភាពនៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ិនធើណែត៖**
សេចក្តីព្រាងច្បាប់នេះបានកំណត់ ទោសព្រហ្មទណ្ឌលើគំនិតដែលរិះគន់រដ្ឋាភិបាល។ នេះមានន័យថា យុវជនអាចត្រូវជាប់គុកដោយសារតែផ្សព្វផ្សាយឬបញ្ចេញមតិនៅលើបណ្តាញ សង្គមហ្វេសប៊ុក ហើយអ្នកសារព័ត៌មានអាចនឹងត្រូវចោទប្រកាន់ពីព័ត៌មានដែលគេផ្សាយតាមប្រព័ន្ធ អ៊ិនធើណែត។ ច្បាប់នេះនឹងគ្របដណ្តប់លើអ្នករាល់គ្នា រួមទាំងអ្នកដែលរស់នៅក្រៅប្រទេសកម្ពុជាផង

**បង្អាក់ការរីកចំរើនផ្នែកសេដ្ឋកិច្ច៖** Google, Facebook និងស្ថាប័នដទៃទៀតបានបង្ហាញក្តីបារម្ភពីកង្វះការការពារលើពាណិជ្ជកម្មអន្តរជាតិដែលកំពុងប្រតិបត្តការក្នុងប្រទេសកម្ពុជា។ សេចក្តីព្រាងច្បាប់នេះក៏ធ្វើអោយក្រុមហ៊ុនបរទេសជាពិសេសក្រុមហ៊ុនបច្ចេកវិទ្យាផ្នែកទំនាក់ទំនងពិបាកបន្តដំឡើងប្រព័ន្ធដំណើរការក្នុងប្រទេសកម្ពុជា ហើយដែលធ្វើអោយវិនិយោគទុនបរទេស និង ឱកាសការងារធ្លាក់ចុះ។



**ដាក់ទោសទណ្ឌលើ ទូរស័ព្ទ កុំព្យូទ័រយួរដៃ និងថេបប្លេត៖** សេចក្តីព្រាងច្បាប់នេះបានធ្វើ អោយការទិញឬលក់ឧបករណ៍ឬកម្មវិធីដែលអាចប្រើដើម្បីប្រព្រឹត្តល្មើសច្បាប់ ជាអំពើខុសច្បាប់។ វាមានដែនសមត្ថកិច្ចលើ កុំព្យូទ័រ ទូរស័ព្ទ ឬកុំព្យូទ័រយួរដៃទាំងអស់។

## អញ្ចឹងតើខ្ញុំអាចធ្វើអ្វីបានខ្លះ?

1. អប់រំខ្លួនអ្នក។ សូមចូលទៅកាន់គេហទំព័រ www.ccimcambodia.org/cybercrime ដើម្បីទទួលបានព័ត៌មានអំពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា។
2. ចុះហត្ថលេខាលើ ញត្តិ។ សុំអោយរដ្ឋាភិបាលបញ្ចេញសេចក្តីព្រាងច្បាប់ផ្លូវការ ហើយអនុញ្ញាតិអោយមានការប្រឹក្សាយោបល់ប្រកបដោយខ្លឹមសារស្តីពីច្បាប់នេះ តាមរយៈគេហទំព័រ www.change.org/p/cybercrime
3. ចែកចាយចំណេះដឹង។ ចាប់ផ្តើមការពិភាក្សា ដោយការចែកចាយឡូហ្គូ និងខិត្តប័ណ្ណព័ត៌មានលើ Facebook